# ការលម្អកលគ (Kalaśa) នៅក្នុងស្ថាបត្យកម្មខ្មែរ (ភាគ២)

នៅភាគទី១នៃប្រធានបទនេះ មានការបង្ហាញពីអត្ថន័យនិងសេចក្តីសំខាន់មួយចំនួនតាមបែបបដិមាសាស្ត្ររបស់កលគជាហូរហែរួចមកហើយ។[១] សម្រាប់ភាគទី២នេះ យើងនឹងមកពិនិត្យលើការយកកលគមកបញ្ចូលទៅក្នុងស្ថាបត្យកម្មខ្មែរនៅសម័យបុរាណបន្ថែមទៀត។

ចំពោះស្ថាបត្យកម្មខ្មែរសម័យបុរាណមានការលម្អដោយកលគ និងចម្លាក់រូបកលគនៅច្រើនកន្លែងណាស់ ពោលគឺមានតាំងពីផ្នែកខឿននៃប្រាសាទរហូតដល់ផ្នែកកំពូលនៃប្រាសាទ។ ជាក់ស្តែងនៅតាមខឿននៃប្រាសាទមួយចំនួននៅមុនសម័យអង្គរ មានការលម្អតួខឿងជាក្បាច់ពេជ្រមូល តែបើសង្កេតឱ្យល្អិតបន្តិច ដោយមើលបន្ថែមជាមួយតួខឿននិងក្បាច់ឈូកផ្ការខាងលើយើងនឹងឃើញថា ខឿនទាំងមូលនោះមានសណ្ឋានស្រដៀងគ្នាទៅនឹងរូបកលគទៅវិញ (**រូបលេខ១**)។ ចំណុចនេះត្រូវគ្នាយ៉ាងខ្លាំងទៅនឹងលក្ខណៈខឿនមួយប្រភេទនៅក្នុងសិល្បៈឥណ្ឌា ដែលគេស្គាល់ជាភាសាសំស្រ្កឹតថា "កលគ Kalaśa" ឬ "កុមុទ Kumuda" ឬ "វល័យ Valaya"។[២]



រូបលេខ១៖ ប្រាសាទគុកព្រះធាតុ ខេត្តកំពង់ចាម (រូបថត៖ ឡេង ស៊ីវ៉ង់)

[១] សូមអានបន្ថែមនៅ៖https://ams.com.kh/khmercivilization/detail/24878

[២] Chedha Tingsanchali 2022: 44-45.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

ផ្នែកសំខាន់មួយទៀតនៃស្ថាបត្យកម្មខ្មែរដែលនិយមលម្អរូបកលគគឺ នៅតាមសសរពេជ្រដែលអមមាត់ទ្វារចូលនៃប្រាសាទខ្មែរ។ ករណីនេះយើងអាចសង្កេតឃើញយ៉ាងច្បាស់នៅតាមបណ្ដាសសរពេជ្រនៅមុនសម័យអង្គរ និងដើមសម័យអង្គរ ដោយច្រើនតែលម្អនៅផ្នែកខាងចុងនិងគល់នៃសសរពេជ្រជារូបកកលគ (**រូបលេខ២២**)។ រូបកលគទាំងនោះនឹងបាត់រូបរាងបន្តិចៗពីលើសសរពេជ្រចាប់ពីពាក់កណ្ដាលសម័យអង្គរទៅ។ ក្រៅពីនៅតាមច្រកចូលប្រាសាទហើយ យើងអាចប្រទះឃើញការលម្អកលគនៅតាមផ្នែកដំបូលនៃប្រាសាទមួយចំនួនផងដែរ ហើយឧទាហរណ៍មួយដែលយើងអាចឃើញដោយច្បាស់គឺកលគនៅកំពូលប្រាសាទបន្ទាយស្រីជាដើម (**រូបលេខ២៣**)។ រូបរាងរបស់កលគនៅតាមកំពូលប្រាសាទនឹងមានការវិវត្តបន្តិចម្ដងៗពីរាងមូលទៅជាក្ខែបៗ សណ្ឋានដូចផ្លែល្ពៅ និងមានការលម្អក្បាច់ត្របកឈូកនៅលើក្ខែបនីមួយៗផងដែរ (**រូបលេខ២៤**)។



រូបលេខ២២៖ សសរពេជ្រនៅប្រាសាទភូមិប្រាសាទ (រូបថត៖ ឡេង ស៊ីវ៉េង)

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង



រូបលេខ៣៖ កលគនៅតាមកំពូលប្រាសាទបន្ទាយស្រី (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ៤៖ កលគពីប្រាសាទព្រះធាតុបារយណ៍ (រូបថត៖ រឿន វណ្ណដេត)

ករណីចម្លាក់មួយប្រភេទទៀតដែលមានសណ្ឋានជាកលគ ហើយគេនិយមយកទៅលម្អនៅតាមព្រំដំបូលនៃសំណង់គឺ នាងប្រាល។ នាងប្រាលជាផ្នែកមួយនៃការលម្អសំណង់បុរាណខ្មែរ មានសណ្ឋានជាបង្គោលខ្លីៗ ផ្នែកខាងក្រោមមានរាងប៉ោងដូចក្អមឬថ្នាំង ទ្រផ្នែកខាងលើមានរាងជាផ្កាឈូកក្រពុំ (**រូបលេខ៥**)។[៣] បើយើងពិចារណារូបរាងរបស់នាងប្រាលដែលមានផ្នែកខាងក្រោមជាភាជន៍សណ្ឋានដូចក្អមឬថ្នាំ ហើយផ្នែកខាងលើមានផ្កាផុសចេញមកនោះឃើញថា គំនិតនេះមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងបូរណកលគ (Pūrṇa Kalaśa) ឬបូរណកុម្ភ (Pūrṇa Kumbha) ឬបូរណឃាត (Pūrṇa Ghaṭa) ដែលជានិមិត្តរូបមង្គលនៃសិល្បៈឥណ្ឌា។ គេច្រើនប្រដាប់នាងប្រាលនៅតាមព្រំដំបូលនៃរោងទង ខ្លោងទ្វារប្រាសាទ ព្រំដំបូលនៃយ៉ប្រាសាទ ទ្រនុងកំពែងប្រាសាទ ឬបណ្ណាល័យប្រាសាទជាដើម (**រូបលេខ៦**)។

[៣] សូមអានបន្ថែមនៅ៖ ព្រាប ចាន់ម៉ារ៉ា ២០១២: ៦២។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



*រូបលេខ២៥៖ នាងប្រាលនៅសារមន្ទីរជាតិគិមាយ (រូបថត៖ ឡេង ស៊ីវ៉ង់)*



*រូបលេខ២៦៖ នាងប្រាលនៅខ្លោងទ្វារប្រាសាទបន្ទាយសំរែ (រូបថត៖ ឡេង ស៊ីវ៉ង់)*

ក្រៅពីនេះយើងសង្កេតឃើញមានការលម្អរូបបូរណកលគនៅតាមហោជាងនិងសំណង់ស្ថាបត្យកម្មមួយចំនួនផងដែរ ជាក់ស្តែងនៅហោជាងប្រាសាទក្រចាប់មានលម្អរូបបូរណកលគចំនួន២នៅអមសងខាងព្រះវារុណ។ រូបបូរណកលគនោះមានរូបរាង ជាផ្ទាំងឬក្អមដែលមានរុក្ខជាដុះចេញមកតាមមាត់ផ្ទាំងឬក្អមនោះ(**រូបលេខ២៧**)។ ចម្លាក់ប្រហែលគ្នានេះក៏ប្រទះឃើញមាននៅតាមកំពូលនៃបង្គោលពុទ្ធាសាសនាមហាយាន និងកំពូលចេតិយមួយចំនួននៅក្នុងសម័យអង្គរនិងចុងសម័យអង្គរផងដែរ (**រូបលេខ២៨**)។



រូបលេខ២៧៖ ហោជាងប្រាសាទក្រចាប់ (រូបថត៖ ពុំ រតនៈពិសិដ្ឋ)



រូបលេខ២៨៖ គោលពុទ្ធសាសនា ពីបន្ទាយមានជ័យ បច្ចុប្បន្ននៅសារមន្ទីរជាតិភ្នំពេញ
(រូបថត៖ ឡេង ស៊ីវ៉ង់)

ជាសរុបមកការប្រើប្រាស់រូបកលគសម្រាប់ការលម្អនៅក្នុងស្ថាបត្យកម្មខ្មែរមានការនិយមរាប់អានយ៉ាងខ្លាំង ព្រោះកលគជានិមិត្តរូបនៃមង្គល តំណាងឱ្យភាពសម្បូរសប្បាយភោគផល កំណើត និងកម្លាំងជីវិតដែលពោរពេញដោយថាមពល។ ហេតុនេះហើយការយករូបកលគទៅលម្អនៅតាមប្រាសាទទំនងជាធ្វើឡើងដើម្បីឱ្យកើតជាមង្គលដល់សំណង់ និងជួយធ្វើឱ្យសំណង់ទាំងនោះកាន់តែមានភាពស័ក្តិសិទ្ធិទៀតផង។ មួយវិញទៀតក៏ប្រហែលជាផ្នែកមួយនៃការឱ្យពរដល់អ្នកដែលបានឆ្លងកាត់ ឬចូលមកកាន់ប្រាសាទផងដែរ៕

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

## បញ្ជីឯកសារយោង

ព្រាប ចាន់ម៉ារ៉ា.

២០១២. *ពាក្យប្រើចំពោះសំណង់បុរាណនិងក្បាច់លម្អ*, ភ្នំពេញ។

ឡេង ស៊ីវ៉ង់.

២០២២. https://ams.com.kh/khmercivilization/detail/24878

Tingsanchali, Chedha.

2022. *Temple in Southeast Asia*. Matichon, Bangkok.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION